ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ៖ ...........................

# ប្រកាស
## ស្តីពី
## តួនាទី ភារកិច្ចរបស់ក្រុមមន្ត្រីជំនួយការនៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៨ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញអនុក្រឹត្យលេខ២៧៣អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ១៤៥សសរ. ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លេខ សសរ ចុះថ្ងៃទី ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការបង្កើតក្រុមការងារជំនាញអន្តរក្រសួងស្ថាប័ន
- តាមសំណើរបស់អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

## សម្រេច

**ប្រការ១**.-ត្រូវបានកំណត់តួនាទីភារកិច្ច ក្រុមមន្ត្រីជំនួយការរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីសម្របសម្រួល ប្រមូលផ្តុំ ពង្រឹងកិច្ចសហការជាមួយក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើ

ជួញដូរមនុស្សរាជធានី ខេត្ត ក្នុងគោលដៅជំរុញនិងលើកកម្ពស់ការអនុវត្តច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ អនុសញ្ញាអន្តរជាតិនានាដែលពាក់ព័ន្ធ មានជាអាទិ៍ពិធីសារស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារដែលបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង(ពិធីសាប៉ាឡឺម៉ូ) និងលិខិតបទដ្ឋានគតិយុត្តិ ជាតិ និងអន្តរជាតិដែលពាក់ព័ន្ធដទៃ។

**ប្រការ ២.**

**ក្រុមមន្ត្រីជំនួយការអគ្គលេខាធិការដ្ឋាន**មានតួនាទី និងភារកិច្ចចម្បង ដូចខាងក្រោម ៖

- ធ្វើជាសេនាធិការជូនអគ្គលេខាធិការដ្ឋាន ដើម្បីធ្វើឲ្យសម្រេចគោលដៅ ផែនការ និងទិសដៅជាយុទ្ធសាស្ត្ររបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ របស់រាជរដ្ឋាភិបាល
- ចូលរួម គាំទ្រ សម្របសម្រួល ប្រមូលផ្តុំកិច្ចសហការរវាងក្រសួងស្ថាប័ន ក្នុងក្រុមការងារជំនាញអន្តរក្រសួងស្ថាប័ន ដើម្បីធានានូវការឯកភាព សុខុដុមនីយកម្ម ប្រសិទ្ធភាព និងនិរន្តរភាពនៃសកម្មភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មកេងប្រវ័ញ្ចលើមនុស្ស ទាំងបុរស ស្ត្រី យុវវ័យ និងកុមារ
- តាមដាន ត្រួតពិនិត្យ វាយតម្លៃសភាពការណ៍ប្រែប្រួលនៃបទល្មើសជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងបទល្មើសពាក់ព័ន្ធដទៃទៀតតាមរយៈកិច្ចអន្តរាគមន៍ ការផ្តល់សេវានានារបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា
- ស្រាវជ្រាវច្បាប់ គោលនយោបាយ លិខិតបទដ្ឋានពាក់ព័ន្ធនានា ពិនិត្យ វាយតម្លៃភាពខ្វះចន្លោះ ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ គោលនយោបាយផែនការ គោលការណ៍ វិធានការ សម្រាប់ការងារបង្ការ ទប់ស្កាត់ ការជួយសង្គ្រោះ និងការពារជនរងគ្រោះ ការបង្ក្រាបបទល្មើស ការផ្តន្ទាទោសជនល្មើស និងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធផ្ទៃក្នុងជាតិ និងអន្តរជាតិ
- សម្របសម្រួល និងតាមដានលទ្ធផលនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគីរវាងប្រទេសពាក់ព័ន្ធ ក្នុងតំបន់ និងជាអន្តរជាតិ
- បូកសរុប វាយតម្លៃ សន្និដ្ឋាន អំពីប្រសិទ្ធភាពនៃការអនុវត្តការងារតាមរយៈកិច្ចសហប្រតិបត្តិការរវាងក្រសួងស្ថាប័ន ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្សគ្រប់រូបភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ។

**ប្រការ ៣.**

ត្រូវបានបែងចែកភារកិច្ច ក្រុមមន្ត្រីជំនួយការអគ្គលេខាធិការដ្ឋាន ដូចខាងក្រោម៖

**ក. ក្រុមមន្ត្រីជំនួយកិច្ចការបង្ការទប់ស្កាត់**

មានភារកិច្ចដូចខាងក្រោម៖

- ចូលរួមជាមួយក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន ទទួលបន្ទុកការងារបង្ការទប់ស្កាត់ ដើម្បីទំនាក់ទំនងសម្របសម្រួល គាំទ្រ សហការ ផ្តល់ និងទទួលព័ត៌មាន តាមដានភាពរីកចម្រើននៃការអនុវត្តសកម្មភាពបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ភាពប្រឈម ពិនិត្យ សន្និដ្ឋាន លើកយោបល់
- សិក្សាស្រាវជ្រាវ ពិនិត្យ តាមដាន សភាពការណ៍ប្រែប្រួលនៃបទល្មើស កលល្បិចជនល្មើស ទំនោរជាសាកលស្តីពីការបង្ការទប់ស្កាត់

៦ សហការតាមដាន ត្រួតពិនិត្យខ្លឹមសារ នៃសាររូបភាពដែលគ្រប់ប្រព័ន្ធផ្សព្វផ្សាយបាន និងកំពុងតែប្រើប្រាស់ជម្រុញ ពង្រីក ឬលើកវិធានការកែលម្អ ដើម្បីធានាប្រសិទ្ធភាពនៃការអប់រំសាធារណជន និងក្រុមគោលដៅនានា ទៅតាមស្ថានភាពភូមិសាស្ត្រ វ័យ កម្រិតនៃការសិក្សាអប់រំ និងស្ថានភាពឯទៀត ក្នុងគោលដៅបង្ការជាមុននិងការពារប្រជាពលរដ្ឋពីអំពើជួញដូរមនុស្ស

3០ សម្របសម្រួល លើកយោបល់ ពាក់ព័ន្ធនឹងការរៀបចំផែនការបង្ការ ទប់ស្កាត់ ស្នើឡើងនូវវិធានការ គោលការណ៍ វិធីសាស្រ្ត យុទ្ធសាស្រ្តទូលំទូលាយដែលត្រូវអនុវត្តសម្រាប់ឲ្យក្រសួង ស្ថាប័ន និងផ្នែកពាក់ព័ន្ធចូលរួមបង្ការទប់ស្កាត់ អំពើជួញដូរមនុស្សនិងអំពើធ្វើកេងប្រវ័ញ្ចលើមនុស្សគ្រប់រូបភាពក្នុងព្រះរាជាណាចក្រកម្ពុជា

- សហការកសាងផែនការអគ្គលេខាធិការដ្ឋាន សកម្មភាពរយៈពេលខ្លី មធ្យម វែង លើកទិសដៅអនុវត្តស្របតាមតំណាក់កាលនីមួយៗ និងកំណត់សូចនាករអនុវត្តសម្រាប់ការងារបង្ការ ទប់ស្កាត់
- ចូលរួមផ្តល់មតិកែលម្អចំណុចខ្វះខាតនៃការអនុវត្តផែនការសកម្មភាព និងយុទ្ធសាស្រ្តនានា និងសហការកសាងផែនការ និងយុទ្ធសាស្រ្តជាតិ រយៈពេល ខ្លីមធ្យមវែង និងដាក់ទិសដៅអនុវត្តស្របតាមតំណាក់កាលនីមួយៗ និងកំណត់សូចនាករអនុវត្តសម្រាប់ការងារបង្ការទប់ស្កាត់ និងជំរុញការអនុវត្ត
- ផ្តួចផ្តើម គាំទ្រ សម្របសម្រួល ការរៀបចំទិវាជាតិយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងយុទ្ធនាការអប់រំ ផ្សព្វផ្សាយជាសាធារណៈនានា

១ ផ្សព្វផ្សាយផែនការ គោលនយោបាយ គោលការណ៍ណែនាំ វិធានការ និងលទ្ធផលការងារនានារបស់គណៈកម្មាធិការជាតិ ជូនសមាជិកនៃក្រុមការងារជំនាញអន្តរក្រសួងស្ថាប័នបានជ្រាប

- តាមដាន បូកសរុប របាយការណ៍ ស្តីពីលទ្ធផលការងារបង្ការទប់ស្កាត់របស់ក្រុមការងារបង្ការទប់ស្កាត់ សន្និដ្ឋាន វាយតម្លៃអំពីប្រសិទ្ធភាព និងលើកអនុសាសន៍ ដាក់ជូនអគ្គលេខាធិការដ្ឋាន
- ចូលរួមប្រជុំទៀងទាត់ជាមួយក្រុមមន្ត្រីជំនួយការផ្សេងទៀត ដើម្បីផ្លាស់ប្តូរយោបល់ និងចែករំលែកព័ត៌មាន និងសហការដោះស្រាយភាពប្រឈមក្នុងការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស
- លើកផែនការការងារ និងថវិកាប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដាក់ជូនលេខាធិការដ្ឋានរដ្ឋបាលសរុប
- ចូលរួមប្រជុំទៀងទាត់ និងរាយការណ៍ការងារជាមួយអគ្គលេខាធិការដ្ឋាន និងបំពេញការងារផ្សេងទៀត តាមការប្រគល់ជូនរបស់អគ្គលេខាធិការដ្ឋាន ។

**ខ. ក្រុមមន្ត្រីជំនួយកិច្ចការការពារជនរងគ្រោះ**

មានភារកិច្ចដូចខាងក្រោម៖

- ចូលរួមជាមួយក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន ទទួលបន្ទុកកិច្ចការពារជនរងគ្រោះ ដើម្បីទំនាក់ទំនងសម្របសម្រួល គាំទ្រ សហការ ផ្តល់ និងទទួលព័ត៌មាន តាមដានភាពរីកចម្រើននៃការអនុវត្តសកម្មភាពជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ភាពប្រឈម ពិនិត្យ សន្និដ្ឋាន និងលើកយោបល់
- សិក្សា ស្រាវជ្រាវ ពិនិត្យ តាមដាន ស្ថានភាពប្រែប្រួលនៃភាពរងគ្រោះរបស់ជនរងគ្រោះ និងជនងាយរងគ្រោះ ទំនោរជាសាកលស្តីពីការការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- ចូលរួមផ្តល់មតិកែលម្អចំណុចខ្វះខាតនៃការអនុវត្តផែនការសកម្មភាព យុទ្ធសាស្រ្តនានា ពាក់ព័ន្ធកិច្ចការពារជនរងគ្រោះ និងការអភិវឌ្ឍន៍កែប្រែស្ថានភាពចាកចេញពីភាពរងគ្រោះ និងសហការ កសាងផែនការ និងយុទ្ធសាស្រ្តជាតិ រយៈពេល ខ្លីមធ្យមវែង និងដាក់ទិសដៅអនុវត្តស្របតាមតំណាក់កាល
- ចូលរួមកសាង គោលការណ៍ បទដ្ឋាន ផែនការ សកម្មភាព យុទ្ធសាស្រ្តសម្រាប់ការជួយជនរងគ្រោះ ផ្តល់កិច្ចការពារផ្លូវច្បាប់ ការផ្តល់សេវាកម្មនានា រួមទាំង សេវាផ្នែកច្បាប់ សេវាសុខភាព សេវាសង្គមកិច្ច ការស្តារនីតិសម្បទា ការធ្វើមាតុភូមិនិវត្តន៍ ការធ្វើសមាហរណកម្ម ទៅក្នុងគ្រួសារ ឬ សហគមន៍ ជំរុញការចងក្រងទិន្នន័យតាមដានករណី ជាប្រព័ន្ធក្នុងកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- ជំរុញការគ្រប់គ្រងមជ្ឈមណ្ឌលជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអនុវត្តបទដ្ឋានអប្បបរមាដែលមានស្រាប់ឲ្យមានប្រសិទ្ធភាព ដើម្បីធ្វើឲ្យប្រសើរឡើងនូវការផ្តល់សេវាកម្មជួយជនរងគ្រោះ ជាពិសេសកុមារ
- ជំរុញការឆ្លើយតបទៅនឹងសំណូមពរ ក្នុងការការពារសិទ្ធិ និងសេចក្តីត្រូវការរបស់ជនរងគ្រោះ ឲ្យមានប្រសិទ្ធភាព និងការទទួលខុសត្រូវ

- សហការ ពិនិត្យតាមដាន លើកយោបល់ ពាក់ព័ន្ធនឹងការរៀបចំផែនការក្នុងការការពារជនរងគ្រោះ ស្នើឡើងនូវវិធានការ គោលការណ៍ វិធីសាស្ត្រ យុទ្ធសាស្ត្រទូលំទូលាយ ដែលត្រូវអនុវត្ត សម្រាប់ក្រសួង ស្ថាប័ន និងវិស័យពាក់ព័ន្ធ ដើម្បីចូលរួមជួយជនរងគ្រោះមិនឲ្យប្រឈមនឹងភាពងាយរងគ្រោះសារជាថ្មី
- ផ្សព្វផ្សាយផែនការ គោលនយោបាយ គោលការណ៍ណែនាំ វិធានការ និងលទ្ធផលការងារនានារបស់គណៈកម្មាធិការជាតិ ជូនសមាជិកនៃក្រុមការងារជំនាញអន្តរក្រសួងស្ថាប័ន
- សហការកសាងផែនការសកម្មភាពអគ្គលេខាធិការដ្ឋាន រយៈពេលខ្លី មធ្យម វែង លើកទិសដៅអនុវត្តស្របតាមតំណាក់កាលនីមួយៗ និងកំណត់សូចនាករអនុវត្តសម្រាប់ការងារជួយជនរងគ្រោះ
- ចូលរួមប្រជុំទៀងទាត់ជាមួយក្រុមមន្ត្រីជំនួយការផ្សេងទៀត ដើម្បីផ្លាស់ប្ដូរយោបល់ និងចែករំលែកព័ត៌មាន និងសហការដោះស្រាយភាពប្រឈមក្នុងការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស
- តាមដាន បូកសរុប របាយការណ៍ ស្ដីពីលទ្ធផលនៃកិច្ចការពារជនរងគ្រោះ សន្និដ្ឋាន វាយតម្លៃអំពីប្រសិទ្ធភាពការងារផ្ដល់សេវាកម្មជួយជនរងគ្រោះ និងអភិវឌ្ឍន៍កែប្រែស្ថានភាព ដាក់ជូនអគ្គលេខាធិការដ្ឋាន
- លើកផែនការការងារ និងថវិកាប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដាក់ជូនលេខាធិការដ្ឋានរដ្ឋបាលសរុប
- ចូលរួមប្រជុំទៀងទាត់ និងរាយការណ៍ការងារជាមួយអគ្គលេខាធិការដ្ឋាន និងបំពេញការងារផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការដ្ឋាន ។

**គ. ក្រុមមន្ត្រីជំនួយកិច្ចការអនុវត្តច្បាប់**

មានភារកិច្ចដូចខាងក្រោម៖

- ចូលរួមជាមួយក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន ទទួលបន្ទុកកិច្ចការអនុវត្តច្បាប់ ដើម្បីទំនាក់ទំនង សម្របសម្រួល គាំទ្រ សហការ ផ្ដល់ និងទទួលព័ត៌មានស្ដីពីភាពរីកចម្រើនក្នុងការអនុវត្តច្បាប់ ភាពប្រឈម ពិនិត្យ សន្និដ្ឋាន លើកយោបល់
- ចែករំលែកជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ព័ត៌មានពាក់ព័ន្ធភាពរីកចម្រើន និងភាពប្រឈមក្នុងការអនុវត្តច្បាប់ ការផ្ដន្ទាទោសបទល្មើសជួញដូរមនុស្ស និងសំណូមពរក្នុងការពង្រឹងកិច្ចការបង្ការ និងបង្ក្រាបតាមនីតិវិធីច្បាប់
- សិក្សាស្រាវជ្រាវការងារផ្នែកច្បាប់ ពាក់ព័ន្ធ ទៅនឹងភាពខ្វះចន្លោះនៃការអនុវត្តក្នុងវិស័យច្បាប់ទាក់ទងនឹងអំពើជួញដូរមនុស្ស
- ជម្រុញ និងពង្រឹងកិច្ចសហការរវាងស្ថាប័នអយ្យការ និងមន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធដើម្បីបម្រើឲ្យការងារបង្ក្រាប និងនីតិវិធីក្នុងការផ្ដន្ទាទោស
- ពិនិត្យតាមដាន លើកយោបល់ ពាក់ព័ន្ធនឹងភាពប្រឈមក្នុងការស្វែងរកភស្តុតាងដាក់បន្ទុក ឬកិច្ចសហការដទៃទៀត ដើម្បីពង្រឹង ពន្លឿន ក្នុងដំណើរការរឿងក្ដីនៅតុលាការ
- សហការជាមួយការិយាល័យតាមដាន និងត្រួតពិនិត្យនីតិវិធី ដើម្បីជំរុញ និងលើកកម្ពស់ប្រសិទ្ធភាពការងារអនុវត្តច្បាប់
- ជំរុញការស៊ើបអង្កេតស្រាវជ្រាវ និងការបង្ក្រាប នាំខ្លួនជនល្មើសមកផ្ដន្ទាទោស ដើម្បីពង្រឹងការអនុវត្តច្បាប់ និងលុបបំបាត់និទណ្ឌភាព ក្នុងគោលបំណងលើកកម្ពស់ការជឿទុកចិត្ត ពីប្រជាពលរដ្ឋ ជាពិសេសជនរងគ្រោះ លើប្រព័ន្ធយុត្តិធម៌ សេវាសង្គម សេវាសាធារណៈ និង ចូលរួមអនុវត្តច្បាប់
- ជម្រុញ តាមដានការអនុវត្តដីការបស់តុលាការក្នុងរឿងក្ដីជួញដូរមនុស្ស
- ផ្សព្វផ្សាយផែនការ គោលនយោបាយ គោលការណ៍ណែនាំ វិធានការ និងលទ្ធផលការងារនានារបស់គណៈកម្មាធិការជាតិ ជូនសមាជិកនៃក្រុមការងារជំនាញអន្តរក្រសួងស្ថាប័ន
- សហការកសាងផែនការសកម្មភាពអគ្គលេខាធិការដ្ឋាន រយៈពេលខ្លី មធ្យម វែង លើកទិសដៅអនុវត្តស្របតាមតំណាក់កាលនីមួយៗ និងកំណត់សូចនាករអនុវត្តសម្រាប់ការងារអនុវត្តច្បាប់

- ចូលរួមប្រជុំទៀងទាត់ជាមួយក្រុមមន្ត្រីជំនួយការផ្សេងទៀត ដើម្បីផ្លាស់ប្តូរយោបល់ និងចែករំលែកព័ត៌មាន និងសហការដោះស្រាយភាពប្រឈមក្នុងការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស
- តាមដាន បូកសរុប របាយការណ៍ ស្តីពីលទ្ធផលការងារកិច្ចការអនុវត្តច្បាប់ សន្និដ្ឋាន វាយតម្លៃអំពីប្រសិទ្ធភាព ដាក់ជូនអគ្គលេខាធិការដ្ឋាន
- លើកផែនការការងារ និងថវិកាប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដាក់ជូនលេខាធិការដ្ឋានរដ្ឋបាលសរុប
- ចូលរួមប្រជុំទៀងទាត់ និងរាយការណ៍ការងារជាមួយអគ្គលេខាធិការដ្ឋាន និងបំពេញការងារផ្សេងទៀត តាមការប្រគល់ជូនរបស់អគ្គលេខាធិការដ្ឋាន ។

**ឃ. ក្រុមមន្ត្រីជំនួយកិច្ចការយុត្តិធម៌**

មានភារកិច្ចដូចខាងក្រោម៖

- ចូលរួមជាមួយក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន ទទួលបន្ទុកការងារកិច្ចការយុត្តិធម៌ ដើម្បីទំនាក់ទំនង សម្របសម្រួល គាំទ្រ សហការ ផ្តល់និងទទួលព័ត៌មានស្តីពីភាពរីកចម្រើននៃការងារក្នុងប្រព័ន្ធយុត្តិធម៌ និងភាពប្រឈម ពិនិត្យ សន្និដ្ឋាន លើកជាយោបល់
- សិក្សា ស្រាវជ្រាវ តាមដាន ស្ថានភាពប្រែប្រួលនៃបទល្មើស សកម្មភាព និងកលល្បិចជនល្មើសដើម្បីសិក្សាអំពីភាពខ្វះចន្លោះនៃច្បាប់ និងលើកយោបល់
- ជំរុញការប្រមូលទិន្នន័យនៃការផ្តន្ទាទោសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
- ពង្រឹងកិច្ចសហការរវាងស្ថាប័នអយ្យការ និងមន្ត្រីនគរបាលយុត្តិធម៌ក្នុងករណីអំពើជួញដូរមនុស្ស
- ចែករំលែកជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ពត៌មានពាក់ព័ន្ធភាពរីកចម្រើន និងភាពប្រឈមក្នុងការអនុវត្តកិច្ចការផ្តន្ទាទោសបទល្មើសជួញដូរមនុស្ស និងសំណូមពរក្នុងការចូលរួមលើកកម្ពស់ប្រព័ន្ធយុត្តិធម៌
- សម្របសម្រួលឲ្យមានកិច្ចសហការជាមួយអន្តរជាតិ ក្នុងការអនុវត្តសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ និងការធ្វើបត្យាប័ន នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ
- សហការផ្តល់យោបល់ ពាក់ព័ន្ធនឹងការរៀបចំផែនការក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ស្នើឡើងនូវវិធានការ គោលការណ៍ វិធីសាស្ត្រ យុទ្ធសាស្ត្រទូលំទូលាយ ដែលត្រូវអនុវត្ត សម្រាប់ក្រសួង ស្ថាប័ន និងផ្នែកពាក់ព័ន្ធ ដើម្បីជំរុញការអនុវត្តច្បាប់ និងការផ្តន្ទាទោសជនល្មើសពាក់ព័ន្ធអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មកេងប្រវ័ញ្ចលើមនុស្សគ្រប់រូបភាព
- ចូលរួមរៀបចំ ផ្តួចផ្តើម គាំទ្រ សម្របសម្រួល បណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់ក្នុងករណីពាក់ព័ន្ធអំពើជួញដូរមនុស្ស
- ផ្សព្វផ្សាយផែនការ គោលនយោបាយ គោលការណ៍ណែនាំ វិធានការ និងលទ្ធផលការងារទាំងឡាយ របស់គណៈកម្មាធិការជាតិ ជូនសមាជិកនៃក្រុមការងារជំនាញអន្តរក្រសួងស្ថាប័ន
- សហការកសាងផែនការសកម្មភាពអគ្គលេខាធិការដ្ឋាន រយៈពេលខ្លី មធ្យម វែង លើកទិសដៅអនុវត្តស្របតាមតំណាក់កាលនីមួយៗ និងកំណត់សូចនាករអនុវត្តសម្រាប់ការងារកិច្ចការយុត្តិធម៌
- ចូលរួមប្រជុំទៀងទាត់ជាមួយក្រុមមន្ត្រីជំនួយការផ្សេងទៀត ដើម្បីផ្លាស់ប្តូរយោបល់ និងចែករំលែកពត៌មាន និងសហការដោះស្រាយភាពប្រឈមក្នុងការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស
- តាមដាន បូកសរុប របាយការណ៍ ស្តីពីលទ្ធផលការងារបង្ការទប់ស្កាត់របស់ក្រុមការងារបង្ការទប់ស្កាត់ សន្និដ្ឋាន វាយតម្លៃអំពីប្រសិទ្ធភាពដាក់ជូនអគ្គលេខាធិការដ្ឋាន
- លើកផែនការការងារ និងថវិកាប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដាក់ជូនលេខាធិការដ្ឋានរដ្ឋបាលសរុប
- ចូលរួមប្រជុំទៀងទាត់ និងរាយការណ៍ការងារជាមួយអគ្គលេខាធិការដ្ឋាន និងបំពេញការងារផ្សេងទៀត តាមការប្រគល់ជូនរបស់អគ្គលេខាធិការដ្ឋាន ។

**ង. ក្រុមមន្ត្រីជំនួយកិច្ចការទេសន្តរប្រវេសន៍**

មានភារកិច្ចដូចខាងក្រោម៖

- ចូលរួមជាមួយក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន ទទួលបន្ទុកការងារទេសន្តរប្រវេសន៍ ដើម្បីទំនាក់ទំនង សម្របសម្រួល គាំទ្រ សហការ ផ្តល់ និងទទួលព័ត៌មាន ស្តីពីភាពរីកចម្រើនក្នុងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពពលករនិងជនរងគ្រោះនៅប្រទេសគោលដៅ ភាពប្រឈម ពិនិត្យ សន្និដ្ឋាន លើកយោបល់
- តាមដាន ស្ថានភាពប្រែប្រួលនៃបទល្មើស កលល្បិចជនល្មើស ទំនោរជាសាកលស្តីពីទេសន្តរប្រវេសន៍ការងារ
- សម្របសម្រួល ជំរុញ និងតាមដានការអនុវត្តអនុសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងការការពារសិទ្ធិ និងផលប្រយោជន៍របស់ពលករទេសន្តប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ ព្រមទាំងកិច្ចព្រមព្រៀង និងអនុស្សរណៈ ដែលបានចុះហត្ថលេខាជាមួយប្រទេសពាក់ព័ន្ធ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃសស្ថានភាពប្រែប្រួលនៃបទល្មើសជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ជាពិសេសស្ត្រី និងកុមារ តាមរយៈរូបភាពទេសន្តរប្រវេសន៍ ព្រមទាំងលើកយោបល់ កែលម្អ និងជំរុញការអនុវត្តឲ្យមានប្រសិទ្ធភាព
- ផ្តួចផ្តើម គាំទ្រ ចូលរួមរៀបចំ សម្របសម្រួល យុទ្ធនាការអប់រំ ផ្សព្វផ្សាយនានា ដែលរៀបចំឡើងដោយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីសុវត្ថិភាពពលករ និងបង្ការភាពរងគ្រោះដោយចំណាកស្រុកប្រថុយប្រថាន
- ផ្សព្វផ្សាយផែនការ គោលនយោបាយ គោលការណ៍ណែនាំ វិធានការ និងលទ្ធផលការងារនានារបស់គណៈកម្មាធិការជាតិ ជូនសមាជិកនៃក្រុមការងារជំនាញអន្តរក្រសួងស្ថាប័ន
- សហការកសាងផែនការសកម្មភាពអគ្គលេខាធិការដ្ឋាន រយៈពេលខ្លី មធ្យម វែង លើកទិសដៅអនុវត្តស្របតាមតំណាក់កាលនីមួយៗ និងកំណត់សូចនាករអនុវត្តសម្រាប់ការងារទេសន្តរប្រវេសន៍
- ចូលរួមប្រជុំទៀងទាត់ជាមួយក្រុមមន្ត្រីជំនួយការផ្សេងទៀត ដើម្បីផ្លាស់ប្តូរយោបល់ និងចែករំលែកព័ត៌មាន និងសហការដោះស្រាយភាពប្រឈមក្នុងការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស
- តាមដាន បូកសរុប របាយការណ៍ ស្តីពីលទ្ធផលការងារទេសន្តរប្រវេសន៍របស់ក្រុមការងារទេសន្តរប្រវេសន៍ សន្និដ្ឋាន វាយតម្លៃអំពីប្រសិទ្ធភាពដាក់ជូនអគ្គលេខាធិការដ្ឋាន
- លើកផែនការការងារ និងថវិកាប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដាក់ជូនលេខាធិការដ្ឋានរដ្ឋបាលសរុប
- ចូលរួមប្រជុំទៀងទាត់ និងរាយការណ៍ការងារជាមួយអគ្គលេខាធិការដ្ឋាន និងបំពេញការងារផ្សេងទៀត តាមការប្រគល់ជូនរបស់អគ្គលេខាធិការដ្ឋាន ។

**ក. ក្រុមមន្ត្រីជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**

មានភារកិច្ចដូចខាងក្រោម៖

- ចូលរួមជាមួយក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន ទទួលបន្ទុកការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីទំនាក់ទំនង សម្របសម្រួល គាំទ្រ សហការ ផ្តល់ និងទទួលពត៌មានស្តីពី ភាពរីកចម្រើនក្នុងការងារសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងភាពប្រឈម សន្និដ្ឋាន លើកយោបល់
- តាមដាន ស្ថានភាពប្រែប្រួលនៃបទល្មើស កលល្បិចជនល្មើសក្នុងករណីជួញដូរមនុស្សឆ្លងដែន
- តាមដាន វាយតម្លៃ និងជំរុញការអនុវត្តផែនការសហប្រតិបត្តិការជាតិ អន្តរជាតិ ទ្វេភាគី ពហុភាគី និងជាមួយបណ្តាប្រទេសពាក់ព័ន្ធ ដើម្បីឆ្លើយតបទៅនឹងបញ្ហាជួញដូរមនុស្ស និងជួយជនរងគ្រោះ
- ពង្រីកការផ្សព្វផ្សាយលទ្ធផលនៃកិច្ចសហប្រតិបត្តិការជាមួយអន្តរជាតិនិងសហការជាមួយក្រុមការងារជំនាញពាក់ព័ន្ធដើម្បីជំរុញការអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈនានាឲ្យមានប្រសិទ្ធភាព
- ចូលរួមរៀបចំ ផ្តួចផ្តើម គាំទ្រ សម្របសម្រួល យុទ្ធនាការអប់រំ ផ្សព្វផ្សាយនានា ដែលរៀបចំឡើងដោយក្រសួងស្ថាប័នពាក់ព័ន្ធ

- ផ្សព្វផ្សាយផែនការ គោលនយោបាយ គោលការណ៍ណែនាំ វិធានការ និងលទ្ធផលការងារនានារបស់គណៈកម្មាធិការជាតិ ជូនសមាជិកនៃក្រុមការងារជំនាញអន្តរក្រសួងស្ថាប័ន
- សហការកសាងផែនការសកម្មភាពអគ្គលេខាធិការដ្ឋាន រយៈពេលខ្លី មធ្យម វែង លើកទិសដៅអនុវត្តស្របតាមតំណាក់កាលនីមួយៗ និងកំណត់សូចនាករអនុវត្តសម្រាប់ការងារសហប្រតិបត្តិការអន្តរជាតិ
- ចូលរួមប្រជុំទៀងទាត់ជាមួយក្រុមមន្ត្រីជំនួយការផ្សេងទៀត ដើម្បីផ្លាស់ប្តូរយោបល់ និងចែករំលែកពត៌មាននិងសហការដោះស្រាយភាពប្រឈមក្នុងការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស
- តាមដាន បូកសរុប របាយការណ៍ ស្តីពីលទ្ធផលការងារបង្ការទប់ស្កាត់របស់ក្រុមការងារបង្ការទប់ស្កាត់ សន្និដ្ឋាន វាយតម្លៃអំពីប្រសិទ្ធភាពដាក់ជូនអគ្គលេខាធិការដ្ឋាន
- លើកផែនការការងារ និងថវិកាប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដាក់ជូនលេខាធិការដ្ឋានរដ្ឋបាលសរុប
- ចូលរួមប្រជុំទៀងទាត់ និងរាយការណ៍ការងារជាមួយអគ្គលេខាធិការដ្ឋាន និងបំពេញការងារផ្សេងទៀត តាមការប្រគល់ជូនរបស់អគ្គលេខាធិការដ្ឋាន ។

**ប្រការ ៣** .

សេចក្តីសម្រេចនេះ អាចបំពេញបន្ថែម ឬកែលម្អតាមការចាំបាច់ និងតាមសំណើសុំរបស់អនុប្រធានអចិន្ត្រៃយ៍ទទួលបន្ទុក ។

**ប្រការ៤**.

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥**.

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រធានក្រុមការងារអន្តរក្រសួងស្ថាប័នទទួលបន្ទុក ការងារបង្ការ ទប់ស្កាត់ ការងារការពារជនរងគ្រោះ ការងារអនុវត្តច្បាប់ ការងារកិច្ចការយុត្តិធម៌ ការងារទេសន្តរប្រវេសន៍ ការងារសហប្រតិបត្តិការអន្តរជាតិ ប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី ខេត្ត មន្ត្រីជំនួយការអគ្គលេខាធិការដ្ឋានទាំងអស់ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និងនគរបាល ប្រធានក្រុមប្រឹក្សានីតិកម្ម ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានភ័ស្តុភារ និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធាននាយកដ្ឋានកណ្តាលមធ្យោបាយ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធាន គ.ជ.ប.ជ**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ
-នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
-ដូចប្រការ១៤
-ឯកសារ កាលប្បវត្តិ